ខិត្តប័ណ្ណព័ត៌មានអំពី

សេចក្តីថ្លែងទំនាក់ទំនងគ្រួសារ

# កិច្ចសន្យាស្នេហ៍



អង្គការសហគមន៍ឥន្ទធនូកម្ពុជា

RUCK

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# តើសេចក្ដីថ្លែងទំនាក់ទំនង គ្រួសារជាអ្វី?



រ៉ក់

និយាយឲ្យខ្លី និងងាយយល់ សេចក្ដីថ្លែងទំនាក់ទំនងគ្រួសារ គឺជាទម្រង់នៃកិច្ចសន្យាឯកជន សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងប្រទេសកម្ពុជាដែលមានបំណងចង់ចុះទុកជាសក្ខីភាពនៃសេចក្ដីស្នេហា និងការប្ដេជ្ញាចិត្តជាគ្រួសាររបស់ខ្លួន។

# ហេតុអ្វីអង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) បង្កើតទម្រង់នេះឡើង?



**រ៉ក់**

ដោយសារប្រទេសកម្ពុជាយើងមិនទាន់មានច្បាប់អនុញ្ញាតិឲ្យអ្នកស្រឡាញ់ភេទដូចគ្នាចុះសំបុត្រអាពាហ៍ពិពាហ៍បាននៅឡើយទេ។ មានលិខិតស្នាមជាអំណះអំណាង វាអាចជួយការពារផលប្រយោជន៍គ្រួសារយើងមួយកម្រិតទៀត។

# ក្ដីស្រឡាញ់មានទំហំលើស មហាសមុទ្រ

## តើកិច្ចសន្យាស្នេហ៍នេះមានសារៈសំខាន់អ្វីខ្លះ សម្រាប់ដៃគូ និងសហគមន៍យើង?



**រ៉ក់**

ស្នេហាផ្អែមល្ហែម ហើយគ្រោះថ្នាក់ក៏មើលមិនឃើញ និយាយតែមាត់អាចភ្លេច សរសេរចំណាំកាន់តែច្បាស់។ បន្ថែមពីបេះដូងស្មោះរបស់យើងការចុះសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារមានប្រយោជន៍ដូចជា៖

- មានឯកសារជាភស្តុតាងផ្លូវការបញ្ជាក់អំពីទំនាក់ទំនងពិតរបស់ដៃគូគ្រួសារភេទដូចគ្នា
- ពង្រឹងនូវប្រសិទ្ធិភាពនៃការដឹងឮ និងទទួលយកពីក្រុមគ្រួសារ និងសហគមន៍ អំពីទំនាក់ទំនងនៃដៃគូភេទដូចគ្នា
- បញ្ជាក់ពីកាតព្វកិច្ចចិញ្ចឹមបីបាច់ និងថែរក្សាកូន ទាំងកូនបង្កើត និងកូនចិញ្ចឹម

## រ៉ក់

- រីតចំណងស្នេហាដោយភក្តីភាពរវាងគូភាគី ព្រមទាំងកំណត់នូវការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក

- ការពារទ្រព្យសម្បត្តិរួមដែលរកបានក្នុងរយៈពេលរួមរស់ជាមួយគ្នា

- ការពារខ្លួន និងក្រុមគ្រួសារពីការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌផ្សេងៗមកលើភាគីណាមួយនៃទំនាក់ទំនងគ្រួសារនេះ ដោយសារតែអំពើរើសអើង

- បញ្ជាក់ពីតម្រូវការចាំបាច់ផ្នែកច្បាប់ជាពិសេសលទ្ធភាពនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនិងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលស្គាល់ ហើយការពារសហព័ទ្ធ និងគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា (សំបុត្រអាពាហ៍ពិពាហ៍តែម្តង)

- បង្ហាញនូវការរស់នៅក្នុងសង្គមដោយស្មើភាពគ្នា គ្មានការរើសអើង និងចេញមុខជាចំហរនៅក្នុងជីវភាពសាមញ្ញ

# តើអ្នកណាខ្លះអាចចុះសេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះបាន?



## រ៉ក់

ស្នេហាគ្មានព្រំដែន មិនប្រកាន់ភេទ យេនឌ័រ ពូជសាសន៍ ពណ៌សម្បុរ ឋានៈសង្គម និងសាសនាឡើយ។ ប្រជាពលរដ្ឋដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ដូចជា ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស និងអ្នកប្តូរយេនឌ័រ។ ពួកគេអាចចុះបាននៅពេលណាដែលពួកគេបានត្រៀមលក្ខណៈរួចរាល់ និងគ្រប់គ្រាន់ក្នុងការបង្កើតគ្រួសារ ហើយស្របតាមលក្ខខណ្ឌមួយចំនួន។

# ដើម្បីចុះសេចក្ដីថ្លែងទំនាក់ទំនង គ្រួសារបានតើត្រូវមានលក្ខខណ្ឌអ្វីខ្លះ?



រ៉ក់

ភាគីទាំងពីរត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

១. ជាបុគ្គលពេញវ័យ មានអាយុចាប់ពី១៨ ឆ្នាំឡើងទៅ

២. មានការស្ម័គ្រចិត្ត និងព្រមព្រៀងដោយគ្មានការបង្ខិតបង្ខំ

៣. ត្រូវរស់នៅជាមួយគ្នាចាប់ពី៣ឆ្នាំឡើងទៅ នៅក្រោមដំបូលផ្ទះតែមួយ

៤. មានការទទួលស្គាល់ ឬដឹងឮ ពីសំណាក់ចាស់ទុំនៅក្នុងភូមិឃុំ។ ប្រសិនបើបានរៀបចំពិធីសែនព្រេន ជប់លៀងអបអរ ឬរៀបការតាមប្រពៃណី ក៏កាន់តែប្រសើរ ពីព្រោះវាជាភស្តុតាងបន្ថែមនៃការដឹងឮពីទំនាក់ទំនងស្នេហា។

# តើតម្រូវឲ្យមានឯកសារអ្វីខ្លះដើម្បីចុះ សេចក្តីថ្លែងទំនាក់ទំនងគ្រួសារបាន?



## រ៉ក់

ឯកសារសំខាន់ៗដែលសម្គាល់អត្តសញ្ញាណរបស់បុគ្គលរួមមាន៖

១. សំបុត្រកំណើត ឬ អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

២. សៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅ

៣. សាក្សី២នាក់ (ដឹងឮពីរយៈពេលនៃការរស់នៅ និងទំនាក់ទំនងស្នេហានៃគូភាគី) ហើយត្រូវចុះនៅចំពោះមុខដៃគូភាគី។

# តើដៃគូភាគីអាចទៅរកទម្រង់សេចក្តីថ្លែងទំនាក់ទំនងគ្រួសារនៅឯណា?



## រ៉ាក់

## អ្នកអាចទំនាក់ទំនងបានតាមរយៈ៖

១. អ្នកទៅសាកសួររកទម្រង់នៅឃុំ/សង្កាត់ នៅតាមបណ្តាខេត្តមួយចំនួនដែលរ៉ាក់បានធ្វើសិក្ខា សាលាផ្សព្វផ្សាយពីការប្រើប្រាស់ទម្រង់នេះជាមួយអាជ្ញាធរដូចជា៖

| ល.រ | ខេត្ត | ឃុំ/សង្កាត់ |
|---|---|---|
| ១ | ស្វាយរៀង | ១. គោកព្រីង ២. ក្រោលគោ ៣. តាសួស ៤. ឈើទាល |
| ២ | ព្រៃវែង | ១. រកា ២. មេសរប្រចាន់ ៣. ព្រៃស្រឡិត |
| ៣ | តាកែវ | ១. ពារាម ២. កណ្តឹង ៣. ត្រពាំងសាប |
| ៤ | កំពត | ១. សត្វហង ២. បឹងនិមល ៣. ដូនយ៉យ |
| ៥ | ព្រះសីហនុ | ១. សង្កាត់១ ២.សង្កាត់២ ៣.សង្កាត់៣ ៤.សង្កាត់៤ |
| ៦ | កំពង់ស្ពឺ | ១. អង្គពពេល ២. រកាកោះ ៣. វាល ៤.ព្រះនិពាន្ត |
| ៧ | កណ្តាល | ១.បារគូ ២. អន្លង់រមៀត ៣.ថ្មី ៤. គោកត្រប់ ៥. បឹងខ្យាង |

## រក់

| ល.រ | ខេត្ត | ឃុំ/សង្កាត់ |
|---|---|---|
| ៨ | កំពង់ឆ្នាំង | ១. អូរឬស្សី ២.ច្រេស ៣.សែប ៤.លង្វែក |
| ៩ | ពោធិ៍សាត់ | ១. ត្រពាំងជង ២.បឹងបត់កណ្តាល ៣. ស្នាមព្រះ ៤. បឹងខ្នារ |
| ១០ | បាត់ដំបង | ១. ជ្រៃ ២. តាលាស់ ៣. មោង ៤.គារ |
| ១១ | ប៉ៃលិន | ១. សាលាក្រៅ |
| ១២ | កំពង់ធំ | ១. កំពង់ក្របៅ ២.ព្រៃតាហ៊ូ ៣. កំពង់រទេះ ៤. អូរកន្ធរ |
| ១៣ | ព្រះវិហារ | ១. កំពង់ប្រណាក ២. ឈានមុខ |
| ១៤ | ឧត្តរមានជ័យ | ១. លំទង ២.ថ្លាត ៣. អន្លង់វែង ៤.ត្រពាំងប្រិយ៍ |
| ១៥ | បន្ទាយមានជ័យ | ១. រលួស ២. ទ្រាល ៣. តាផូ ៤.ស្វាយចេក |
| ១៦ | ត្បូងឃ្មុំ | ១. ជប់ ២.ស្រឡប់ ៣.ល្វៀង ៤.អញ្ចើម |
| ១៧ | កំពង់ចាម | ១. សូទិព្វ ២.ព្រីងជ្រុំ ៣.ស្ដើងជ័យ |
| ១៨ | ស្ទឹងត្រែង | ១. ថាឡាបរិវ៉ាត ២. សំអាង ៣. អូររៃ ៤. ស្រែឬស្សី |
| ១៩ | ភ្នំពេញ | ១. ដង្កោ ២. ជើងឯក |
| ២០ | សៀមរាប | ១.សាលាកំរើក ២.គោកចក ៣. ស្លក្រាម |

២. អ្នកអាចផ្ញើការទាក់ទងមកការិយាល័យអង្គការសហគមន៍ឥន្ទធនូកម្ពុជា ដើម្បីស្នើសុំទម្រង់តាមរយៈអាសយដ្ឋាននៃខិតប័ណ្ណខាងក្រោម។

# តើរបៀបនៃការចុះសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារត្រូវធ្វើដូចម្ដេចខ្លះ?



រ៉ក់

បន្ទាប់ពីមានទម្រង់សេចក្ដីថ្លែងទំនាក់ទំនងគ្រួសារនៅក្នុងដៃរួចហើយ ភាគីទាំងពីរអាចរកឪពុកម្ដាយ ឬ បងប្អូន សាច់ញាតិរបស់ភាគីខាងណាម្នាក់ ឬ ទាំងសងខាងដើម្បីធ្វើជាសាក្សី ។ បន្ទាប់មក ភាគីទាំងពីរ និងសាក្សី ទៅធ្វើសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារនៅចំពោះមុខមេភូមិចុងក្រោយទៅជួបមេឃុំ ដើម្បីស្នើសុំគាត់ធ្វើការបញ្ជាក់ពីស្នាមមេដៃរបស់មេភូមិពិតប្រាកដមែន។

# ប្រសិនបើអាជ្ញាធរភូមិ និងឃុំ បដិសេធ តើគូភាគីគួរទៅរកអ្នកណា?



**រ៉ក់**

អ្នកគួរតែដកថយសិន ហើយមកពិនិត្យមើលថា តើក្នុងភូមិនេះអ្នកណា ដែលទទួលបាននូវការគោរពពីអ្នកផងទាំងពួងដូចជា អតីតមេភូមិ អនុប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ អាចារ្យ ព្រះសង្ឃ ឬ ចាស់ព្រឹទ្ធាចារ្យ ដើម្បីឲ្យលោកចូលរួមដឹងឮនៅលើ សេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះ។

មេភូមិនិងមេឃុំ/ចៅសង្កាត់ជាសាក្សីអាទិភាព ដែលអ្នកត្រូវពឹងពាក់មុនគេ ដោយហេតុថា លោកគឺជាអាជ្ញាធរមូលដ្ឋាន ដែលធ្វើឲ្យ សេចក្តីថ្លែងទំនាក់ទំនងគ្រួសារនេះមាន លក្ខណៈទទួលស្គាល់កាន់តែទូលំទូលាយ។

# តើរាជរដ្ឋាភិបាលកម្ពុជាបានដឹង និងគាំទ្រ សេចក្ដីថ្លែងទំនាក់ទំនង គ្រួសារបែបណា?



រ៉ក់

ដូចបានរៀបរាប់អង្គការសហគមន៍ឥន្ទធនូកម្ពុជា បានអនុវត្តសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារជាមួយ អាជ្ញាធរតាមខេត្តតាមរយៈសិក្ខាសាលាផ្សព្វផ្សាយ ចាប់ពីឆ្នាំ២០១៦មក។ នៅក្នុងកិច្ចសន្ទនាចំនួន ពីរដងស្ដីពី «**ច្បាប់ និងគោលនយោបាយសាធារណៈគាំពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា**» នៅក្នុងឆ្នាំ២០១៨ និង ២០១៩ ជាមួយក្រសួងស្ថាប័នជាតិចំនួន៦។ នៅក្នុងនោះ ក្រសួងមហាផ្ទៃតាមរយៈអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម បានទទួលស្គាល់ពីទម្រង់នៃសេចក្ដីថ្លែងទំនាក់ទំនងគ្រួសារនេះថាជាទម្រង់នៃកិច្ចសន្យាឯកជនសម្រាប់ដៃគូស្រឡាញ់ភេទដូចគ្នា ហើយលើកទឹកចិត្តឲ្យបុគ្គលដែលមានលក្ខណៈគ្រប់គ្រាន់ប្រើប្រាស់នៅថ្នាក់មូលដ្ឋានតាមលទ្ធភាព។

# ព័ត៌មានបន្ថែម៖

វីដេអូបង្ហាញពីដំណើរការនៃការចុះសេចក្តីថ្លែង ទំនាក់ទំនងគ្រួសារ https://youtu.be/p1TTptvx6lY

គេហទំព័រ : http://www.rockcambodia.org/

ទំព័រហ្វេសប៊ុក : @RoCKHMERLGBT2009

លេខទូរស័ព្ទ : ០១២ ៤៨១ ៥៦១
០៩០ ៨៧៥ ៩២៩

អាសយដ្ឋាន : ផ្ទះលេខ ៥0D ផ្លូវ៤៥៦
សង្កាត់ទួលទំពូង២ ខណ្ឌចំការមន
រាជធានីភ្នំពេញ

ផលិតនៅឆ្នាំ២០២១

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
ROCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION